# វ៉ាក់សាំង COVID-19

## អ្នកត្រូវដឹងក្បោះក្បាយ អំពីវ៉ាក់សាំង COVID-19*

### វាគឺមានសុវត្ថិភាព

**សព្វថ្ងៃនេះមានវ៉ាក់សាំង COVID-19 និងត្រូវបានយល់ព្រម និងត្រូវបានឲ្យអនុសាសន៍ដោយ FDA និងគណៈម្មាធិការរបស់ CDC ស្តីពីការអនុវត្តន៍ចាក់ថ្នាំការពាររោគ ដោយធ្វើតាមមាត្រដ្ឋាន ការសាកល្បង និងនីតិវិធីការយល់ព្រម។**

ដោយតាមអាទិភាពនៃធនធាន និងការខំប្រឹងប្រែង វ៉ាក់សាំងត្រូវបានផលិតយ៉ាងឆាប់រហ័ស និងមិនដែលលះបង់នូវសុវត្ថិភាពឡើយ។ សំរាប់សេចក្តីពិស្តារថែមទៀត ស្តីពីសុវត្ថិភាពវ៉ាក់សាំង ទស្សនា **mass.gov/COVIDVaccineSafety**

### វាគឺឥតគិតថ្លៃ

**វ៉ាក់សាំង COVID-19 គឺកំពុងតែបានចាក់ដោយឥតគិតថ្លៃ ទៅដល់បុគ្គលទាំងអស់ នៃរដ្ឋាភិបាលសហព័ន្ធ។**

ព័ត៌មានការធានារ៉ាប់រង អាចនឹងបានសួរ ដោយអ្នកដែលចាក់វ៉ាក់សាំងឲ្យ ដើម្បីចេញវិក្កយប័ត្រ បកទៅក្រុមហ៊ុនធានារ៉ាប់រង។ តែយ៉ាងណាមិញ អ្នកនឹងមិនត្រូវបានទារថ្លៃឡើយ។ បើសិនអ្នកពុំមានការធានារ៉ាប់រងទេ អ្នកនៅតែមានសិទ្ធិទទួលវ៉ាក់សាំងបាន ដោយឥតទារថ្លៃ។

### ដើម្បីឲ្យបានចាក់វ៉ាក់សាំងពេញលេញ អ្នកត្រូវការពីរដូស្ស

**ទំរាំនឹងអ្នកបានចាក់វ៉ាក់សាំងពេញលេញ អ្នកនៅតែអាចកើត និងចំឡងជំងឺ COVID-19 ទៀត។**

មិនមែនគ្រប់ៗគ្នានឹងបានចាក់វ៉ាក់សាំង នៅពេលអ្នកចាក់ឡើយ។ ហើយក្នុងខណៈយើងដឹងថាវាបន្ថយករណី និងរោគសញ្ញាធ្ងន់ធ្ងរ សន្ទឹកសន្ធាប់ យើងក៏នៅតែកំពុងសិក្សា អំពីការការពារដែលវ៉ាក់សាំង COVID-19 ផ្តល់ឲ្យ នៅក្រោមលក្ខណៈជីវិតពិត។ ចូរបន្តពាក់ម៉ាស្ក លាងដៃរបស់អ្នក រក្សាគម្លាត និងជៀសវាងក្រុមមនុស្ស នៅចន្លោះពេលនៃដូស្សនិមួយៗ និងសូម្បីតែបន្ទាប់ពីដូស្សទីពីរ។

### ដូស្សទីពីររបស់អ្នក ត្រូវការបានចាក់មកពីទីតាំងដូចគ្នា

**អ្នកត្រូវតែទទួលដូស្សទីពីររបស់អ្នក នូវវ៉ាក់សាំងដូចគ្នា នៅទីតាំងដូចគ្នា នឹងលើកដំបូងរបស់អ្នក។**

- **វ៉ាក់សាំង Pfizer៖ 21 ថ្ងៃ** ក្រោយពីដូស្សទីមួយ
- **វ៉ាក់សាំង Moderna៖ 28 ថ្ងៃ** ក្រោយពីដូស្សទីមួយ

ដូច្នេះហើយ មុននឹងចាកចេញពីការណាត់ជួប នៃការចាក់ដូស្សទីមួយរបស់អ្នក ត្រូវគ្រោងពេល ឬបញ្ជាក់របៀប ដើម្បីរៀបចំការណាត់ជួបរបស់អ្នក លើកក្រោយទៀត។

### រកឲ្យដឹងពេលវេលា ដែលអ្នកអាចបានចាក់វ៉ាក់សាំង នៅ mass.gov/covidvaccinephases

**រដ្ឋម៉ាស្សាជូសេត្ត បានបង្កើតដំណាក់កាល ចិរវេលាការចែកចាយវ៉ាក់សាំង COVID-19 ដោយផ្តោតលើយុត្តិធម៌ និងសុវត្ថិភាព។**

ចិរវេលាផ្តោតលើការរក្សា សមត្ថភាពប្រព័ន្ធសុខាភិបាល, ការដោះស្រាយភាពអយុត្តិធម៌ ក្នុងការទទួលថែទាំសុខភាព និងបន្ទុកជំងឺ COVID-19, និងការពារប្រជាជនដែលងាយរងគ្រោះ។ ដំណាក់កាលនិមួយៗ មានក្រុមជាអាទិភាព នៅក្នុងវា។ សំរាប់ក្រុមជាអាទិភាព បានទាន់បច្ចុប្បន្នភាព យ៉ាងទៀងទាត់ និងការងារមានសិទ្ធិចាក់ និងលក្ខណៈសុខភាព ទស្សនា **mass.gov/COVIDVaccinePhases**

* ព័ត៌មាននេះបានទាន់បច្ចុប្បន្នភាព ចុងក្រោយនៅ 1/14/21 និងអនុវត្តចំពោះវ៉ាក់សាំង Moderna និង Pfizer។

**សំរាប់ព័ត៌មានថែមទៀត ស្តីពីវ៉ាក់សាំង COVID-19, ដំណាក់កាល, និងច្រើនទៀត ទស្សនា mass.gov/COVIDVaccinePhases**